# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីទីតាំងការិយាល័យកណ្ដាល នគរបាលយុត្តិធម៌នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ទីតាំងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និង ទីតាំងមន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ១២៩៧ សស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ១២៩៦ សស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ២៧២ សក.ហរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងការិយាល័យកណ្ដាលនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ទីតាំងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និង ទីតាំងមន្ទីរសាធារណការ និងដឹកជញ្ជូន ក្រុងព្រះសីហនុ ដើម្បីធ្វើការដោះដូរជាមួយផ្ទះរបស់ភាគីឯកជន ។

**មាត្រា ២.-**

ការកត់ត្រាទ្រព្យសម្បត្តិថ្មីរបស់ការិយាល័យកណ្ដាលនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និង មន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងព្រះសីហនុ ទៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និង ដឹកជញ្ជូន សាលាខេត្តសៀមរាប សាលាខេត្តបាត់ដំបង សាលាក្រុងព្រះសីហនុ និង មន្ទីរជំនាញពាក់ព័ន្ធ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

ការបំពេញបែបបទផ្ទេរកម្មសិទ្ធិរបស់ភាគីឯកជន ទៅលើទីតាំងរបស់រដ្ឋ ដូចមានកំណត់នៅក្នុងមាត្រា ១ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន អភិបាលខេត្តសៀមរាប អភិបាលខេត្តបាត់ដំបង និង អភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៨

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ